ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

KINGDOM OF CAMBODIA

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

Ministry of Commerce

No. 260 MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី 4 ខែ សីហា ឆ្នាំ ២០០៤

# ប្រកាស

## ស្តីពី

## ការទប់ស្កាត់សកម្មភាពឆ្លៀតឆ្លង ដែលប៉ះពាល់ដល់ព្រះពុទ្ធសាសនា

## ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០២/០០៦ ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០២ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- បានឃើញអនុក្រឹត្យលេខ ៥៤អនក្រ-បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមតំរូវការចាំបាច់ក្នុងការជួយថែរក្សា និង លើកកំពស់កិត្យានុភាពព្រះពុទ្ធសាសនា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

## សំរេច

**ប្រការ១:** មាត្រា ៤៣ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាចែងថា ព្រះពុទ្ធសាសនាជាសាសនា របស់រដ្ឋ។ មាត្រា ៤(ខ) នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និង អំពើនៃការប្រកួតប្រជែងមិន ស្មោះត្រង់ ចែងថា ម៉ាកដែលពុំអាចចុះបញ្ជីបានគឺ ម៉ាកទាំងឡាយណាដែលប៉ះពាល់ដល់ សណ្តាប់ធ្នាប់សាធារណៈ សីលធម៌ ឬប្រពៃណីល្អរបស់ជាតិ។ ដូច្នេះរាល់សកម្មទាំងឡាយ រួមទាំងសកម្មភាព ផ្នែកពាណិជ្ជកម្ម ផលិតកម្ម



Ministry of Commerce # 20 A & B Preah Norodom Boulevard. Phnom Penh 12205 ( Kingdom of Cambodia )
Minister's Mobile Phone (855-12) 821888 Facsimile: (855-23) 213288
URL : http //www.moc.gov.kh E-Mail : champrasidh@hotmail.com
Staff's Mobile Phones: (855-12) 933 323 / 881223 Facsimile (855-23) 426396

សេវាកម្ម និង សកម្មភាព សាធារណៈដ៏ទៃទៀត ដូចជាការសំដែងសិល្បៈរបាំ ប្រគុំដូរ្យតន្ត្រី។ល។ ដែលធ្វើអោយ ប៉ះពាល់ ដល់ការគោរព បូជាចំពោះព្រះពុទ្ធសាសនា ត្រូវបានចាត់ទុកថាជាសកម្មមាក់ងាយ ដល់ព្រះពុទ្ធសាសនា និង ប៉ះពាល់ដល់ប្រពៃណីជាតិ ។

**ប្រការ២:** ដោយយោងតាមខ្លឹមសារនៃប្រការ ១ ខាងលើ រាល់ការនាំចូល ការផលិត ការតាំងលក់ និង ការផ្សព្វផ្សាយពាណិជ្ជកម្មតាមមធ្យោបាយផ្សេងៗ នូវផលិតផលជាសំភារៈប្រើប្រាស់ ផលិតផលតាំងលំអរូបភាពឃោសនា ភេសជ្ជៈ គ្រឿងស្រវឹង ដែលប្រើរូបភាព និង រូបលំនាំ (Caricature) រូបថ្លុកពាក់ព័ន្ធនឹងព្រះពុទ្ធសាសនា ជាពិសេសការនាំចូល ការផលិត ការតាំងលក់ ខោខ្លីសំរាប់មុជទឹករបស់នារី ទៀនសំរាប់អុជក្នុងករណីផ្សេងក្រៅពីការបូជាព្រះពុទ្ធសាសនា ស្រាបៀរ សុរា ដែលមានបោះពុម្ព រូបភាពព្រះពុទ្ធនៅពីលើ និង ថាសចំរៀងដែលមាន ឈ្មោះថា " **Buddha Bar** " ត្រូវបានហាមឃាត់ជាដាច់ខាត ។

**ប្រការ៣:** ទង្វើទាំងឡាយណារបស់ អាជីវករ ផលិតករ សេវាករ ដែលផ្ទុយទៅនឹងការណែនាំក្នុង ប្រការ ២ខាងលើ ត្រូវចាត់ទុកជាអំពើល្មើស ហើយនឹងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ និង បទប្បញ្ញត្តិ ជាធរមានរបស់ព្រះរាជាណាចក្រកម្ពុជា ។

**ប្រការ៤:** នាយកដ្ឋានកាំកុងត្រូល និងនាយកដ្ឋានកម្មសិទ្ធិបញ្ញា ត្រូវសហការណ៍ជាមួយស្ថាប័នមានសមត្ថកិច្ច ដែលពាក់ព័ន្ធផ្សេងៗទៀត រាំងខ្ទប់នូវអំពើល្មើសទាំងឡាយ ដូចមានចែងក្នុងប្រការ២ នៅតាមមាត់ច្រកព្រំដែន និងនៅលើទីផ្សារនៃព្រះរាជាណាចក្រកម្ពុជា អោយ ទទួលបានប្រសិទ្ធភាពខ្ពស់ ។

**ប្រការ៥:** ប្រកាសនេះចូលជាធរមាន ចាប់ពីពេលចុះហត្ថលេខាតទៅ ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**<u>ចំលងជូន</u>**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សោ ខេង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- ក្រសួងធម្មការ និង កិច្ចការសាសនា
- ទីចាត់ការគយ និង រដ្ឋាករ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ